ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ ៤៤៧២ អដល.ទរក.ទប

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា ជាក្រុមហ៊ុនរបស់រដ្ឋដែលមានសិទ្ធិក្នុងការផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា តាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា។ អគ្គិសនីកម្ពុជាបច្ចុប្បន្នមាននិយោជិតជាង ៣០០០នាក់ ហើយជាក្រុមហ៊ុនមួយដែលកំពុងជម្រុញវឌ្ឍនភាពវិស័យថាមពលឲ្យបានលឿនទៅមុខយ៉ាងសកម្ម។ អគ្គិសនីកម្ពុជា បាននឹងកំពុងអនុវត្តកម្មវិធីកែទម្រង់របស់ខ្លួនយ៉ាងស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយដែលក្រុមហ៊ុនបានដណ្តើមបាននូវសមិទ្ធិផលធំៗជាច្រើនដែលជាប្រវត្តិសាស្ត្រជូនប្រទេសជាតិ ប្រជាជន និងក្រុមហ៊ុនផ្ទាល់។

ដើម្បីឆ្លើយតបទៅនិងតម្រូវការការងារ អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជាត្រូវការជ្រើសរើសបុគ្គលិកចំនួន ០១រូប ដើម្បីចូលបម្រើការងារនៅលេខាធិការដ្ឋានអគ្គនាយកនៃអគ្គិសនីកម្ពុជាដូចខាងក្រោម៖

**តួនាទី៖** អនុប្រធានលេខាធិការដ្ឋានអគ្គនាយក

### ភារកិច្ចនិងការទទួលខុសត្រូវ៖

- ជំនួយការអគ្គនាយកក្នុងលេខាធិការដ្ឋានអគ្គនាយកក្នុងការងារទូទៅជាពិសេសការងារសហប្រតិបត្តិការ ជាមួយបណ្តាក្រុមហ៊ុនដៃគូអភិវឌ្ឍន៍នានា
- ជំនួយការក្នុងការងារលេខាធិការដ្ឋានអគ្គនាយកក្នុងដំណើរការប្រចាំថ្ងៃ រាប់ទាំងការគាំទ្រដំណើរការប្រជុំក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា
- ទទួលជួយពិនិត្យលិខិតស្នាម ឯកសារនានាឲ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ
- បំពេញការងារផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឲ្យ

### តម្រូវការជំនាញអប្បបរមា៖

- បរិញ្ញាបត្រជាន់ខ្ពស់ (Master's Degree) ក្នុងជំនាញវិទ្យាសាស្ត្រសង្គមណាមួយពីសាកលវិទ្យាល័យដែលមានការទទួលស្គាល់ ហើយបើមានការបណ្តុះបណ្តាលពីបរទេសជាការប្រសើរ
- ចេះស្ទាត់ជំនាញខាងកុំព្យូទ័រជាពិសេស Microsoft Office ហើយស្ទាត់ខាង Khmer Unicode
- ចេះភាសាអង់គ្លេសទាំងនិយាយ និងសរសេរ ( TOEFL≥550; IELTS ≥6.5 )
- អាចធ្វើដំណើរ ( តាមខេត្ត និងបរទេស )
- អាចធ្វើការជាក្រុម និងដោយឯករាជ្យតាមការចាំបាច់
- មានអត្តចរិតល្អ និងសកម្មក្នុងការបំពេញការងារ
- បើចេះភាសាចិនកាន់តែប្រសើរ

ជាស្ត្រីដែលមានអាយុចាប់ពី ២០ឆ្នាំ ដល់ ៣០ឆ្នាំ

**អត្ថប្រយោជន៍៖**

- ប្រាក់បៀវត្សរ៍សមរម្យតាមគោលការណ៍របស់អគ្គិសនីកម្ពុជា
- ឱកាសចូលរួមការងារផ្ទាល់ជាមួយអគ្គនាយកក្នុងការជួយកសាងជាតិ
- រៀនសូត្រ និងពង្រីកសក្តានុពលផ្នែកដឹកនាំ និងគ្រប់គ្រង

**បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ៖**

- ពាក្យសុំចូលបម្រើការងារ មានបិទតែមប្រ៊ី (១.០០០រៀល) ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤x៦ ចំនួន ០១ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬអាចជាសៀវភៅគ្រួសារឬអត្តសញ្ញាណប័ណ្ណ (ច្បាប់ចម្លងមានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត) ឬលិខិតបញ្ជាក់ទីលំនៅចុះហត្ថលេខាពីខណ្ឌ-ស្រុក ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់កិរិយាមារយាទ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់សុខភាព(ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត ចំនួន ០១ ច្បាប់
- តារាងពិន្ទុ (TRANSCRIPT) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ ឬ ច្បាប់ចម្លងសញ្ញាប័ត្រផ្សេងៗ (បើមាន) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) ចំនួន ០១ ច្បាប់

**ទីកន្លែងទទួលពាក្យ: សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា**

**ចាប់ផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ រៀងរាល់ថ្ងៃធ្វើការ**

- ពេលព្រឹក ចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ១១:៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤:០០ ដល់ម៉ោង ១៧:០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់អគ្គិសនីកម្ពុជា ។

**ព័ត៌មានផ្សេងៗ:** សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាលអគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ: ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១ ។

**បញ្ជាក់៖** មានតែបេក្ខភាពដែលបំពេញបានតាមតម្រូវការអប្បបរមាទេ ដែលត្រូវបានអញ្ជើញមកសម្ភាសន៍ បេក្ខជនដែលជាបុគ្គលិកអគ្គិសនីកម្ពុជាស្រាប់ ត្រូវបានលើកទឹកចិត្តឲ្យចូលរួម។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១៥

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**